雲南日報 报业集团
YUNNAN DAILY PRESS GROUP ១២

# ប្រទេសចិន-ខេត្តយូណាន

magazinekh@163.com
kh.yunnangateway.com

កោះសន្តិភាព | លេខ ៤ ថ្ងៃ ព្រហស្បតិ៍ ទី ១១ ខែ សីហា ឆ្នាំ ២០២២

ព័ត៌មាន — ដោយ ៖ ទីភ្នាក់ងារព័ត៌មានស៊ីនហួ

## ស្បៀវភៅ<<ស៊ី ជីនភីង ៖ អភិបាលកិច្ចប្រទេសចិន>> (ភាគទី ៤)ជាភាសាចិន និងភាសាអង់គ្លេស បានត្រូវបោះពុម្ពផ្សាយជាផ្លូវការ

ពេលថ្មីៗនេះ សៀវភៅ«ស៊ីជីនភីង៖អភិបាលកិច្ចប្រទេសចិន» (ភាគទី ៤) ជាភាសាចិន និងភាសាអង់គ្លេស បានត្រូវបោះពុម្ពផ្សាយជាផ្លូវការនៅក្នុង និងក្រៅប្រទេសចិន។

សៀវភៅ«ស៊ី ជីនភីង ៖ អភិបាលកិច្ចប្រទេសចិន»(ភាគទី ៤)នេះ បានចងក្រងនូវអត្ថបទចំនួន ១០៩ ដែលត្រូវបានចែកជាប្រធានបទពិសេសចំនួន ២១ របស់ឯកឧត្តម ស៊ី ជីនភីង ប្រធានាធិបតីចិន ក្នុងអំឡុងពេលពីថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០២០ ដល់ថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០២២ ដែលក្នុងនោះមានសុន្ទរកថា ការសន្ទនា ការចង្អុលបង្ហាញ និងសារលិខិតជូនពរជាដើម។ លើសពីនេះទៀត ដើម្បីនាំមកនូវភាពងាយស្រួលដល់មិត្តអ្នកអាន និងអាចយល់ដឹងអត្ថបទកាន់តែល្អប្រសើរ ក្នុងនោះបានបន្ថែមអំណានបន្ថែមចាំបាច់នាពេលនិពន្ធសៀវភៅ។ ជាងនេះទៅទៀត សៀវភៅនេះបានចងក្រងរូបភាពចំនួន ៤៥ សន្លឹករបស់ឯកឧត្តមប្រធានាធិបតីចិន ស៊ី ជីនភីង តាំងពីខែមករា ឆ្នាំ ២០២០ មក៕

ប្រទេសចិនក្នុងទសវត្សរ៍នេះ — ដោយ ៖ ទីភ្នាក់ងារព័ត៌មានស៊ីនហួ

## ខេត្តយូណានបោះជំហានថ្មីក្នុងការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់



យោងតាមដំណឹងពីសន្និសីទសារព័ត៌មានក្រោមប្រធានបទ“ប្រទេសចិនក្នុងទសវត្សរ៍នេះ•យូណាន” បានឱ្យដឹងថា ចាប់តាំងពីឆ្នាំ ២០១២ មក ខេត្តយូណានបានអនុវត្តយ៉ាងស៊ីជម្រៅនូវស្មារតីនៃការចង្អុលបង្ហាញសំខាន់ៗរបស់ឯកឧត្តម ស៊ី ជីនភីង ប្រធានាធិបតីចិន ដែលជំរុញឱ្យការបោះជំហានថ្មី ក្នុងការអភិវឌ្ឍជឿនលឿនប្រកបដោយគុណភាពខ្ពស់ ដោយផ្តោតសំខាន់ទៅលើកម្លាំងសេដ្ឋកិច្ចចម្រុះ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍនៃឧស្សាហកម្មលក្ខណៈពិសេស ការស្ថាបនាអរិយធម៌អេកូឡូស៊ី ការកែលម្អសន្តិសុខជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលបានទទួលលទ្ធផលគួរឱ្យគត់សម្គាល់ក្នុងប្រវត្តិសាស្ត្រ។

ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ទំហំសេដ្ឋកិច្ចសរុបទូទាំងខេត្តយូណានត្រូវបានកើនឡើងពី ១,១ ទ្រីលានយន់ក្នុងឆ្នាំ ២០១២ ទៅ ២,៧១ ទ្រីលានយន់ក្នុងឆ្នាំ ២០២១។ ថាមពលបៃតងបានក្លាយជាឧស្សាហកម្មធំបំផុត ឯកសិកម្មលក្ខណៈពិសេសតំបន់ខ្ពង់រាប មានដូចជា ការដាំដុះស្លឹកតែ និងផ្កាកាត់ស្រស់ បានបន្តរីកចម្រើនឥតឈប់ឈរ។ នៅខេត្តយូណាន ចម្ងាយផ្លូវល្បឿនលឿនមានប្រវែងលើសពី ១ ម៉ឺនគីឡូម៉ែត្រ ផ្លូវថ្នល់ក្នុងជនបទមានប្រវែងលើសពី ២៦ ម៉ឺនគីឡូម៉ែត្រ សុទ្ធតែជាប់ចំណាត់ថ្នាក់លេខពីរក្នុងប្រទេសចិន។

ខេត្តយូណានប្រកាន់ខ្ជាប់ក្នុងការយកការកាត់បន្ថយភាពក្រីក្រជាកិច្ចការអាទិភាព។ ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ប្រជាជនក្រីក្រនៅជនបទទូទាំងខេត្តយូណានចំនួន ៩,៣៣ លាននាក់ ត្រូវបានដកចេញពីភាពក្រីក្រទាំងអស់ ភូមិក្រីក្រចំនួន ៨.៥០២ និងស្រុកក្រីក្រចំនួន ៨៨ បានលុបចេញពីបញ្ជីឈ្មោះទាំងអស់ ប្រជាជនក្រីក្រចំនួន ១,៥ លាននាក់ផ្លាស់ប្តូរទៅរស់នៅក្នុងគេហដ្ឋានថ្មីដោយបានដោះស្រាយបញ្ហាក្រីក្រដាច់ខាត។

ខេត្តយូណានក៏បានអនុវត្តកិច្ចការពន្លឿនក្នុងការតភ្ជាប់នឹងផែនការសកម្មភាព RCEP ហើយបានចូលរួមយ៉ាងស៊ីជម្រៅក្នុងការកសាងតំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន ចំពោះច្រករបៀងធំអន្តរជាតិ ចិន-មីយ៉ាន់ម៉ា ចិន-ឡាវ និងចិន-វៀតណាម ផ្លូវល្បឿនលឿនក្នុងប្រទេសចិនត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការទាំងស្រុង ខេត្តយូណានបានបើកខ្សែផ្លូវអាកាសចរណ៍ជាមួយទីក្រុងនៅតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ចំនួនទីក្រុងបានជាប់ចំណាត់ថ្នាក់លេខ ១ ក្នុងទូទាំងប្រទេសចិន ផ្លូវដែកចិន-ឡាវបានដាក់ឱ្យប្រើប្រាស់ និងចាប់ដំណើរការ ការបើកចំហរចំពោះបរទេសនៃខេត្តយូណានបន្តឆ្ពោះទៅមុខគ្រប់ទិសដៅ ពហុវិស័យ និងក្នុងកម្រិតស៊ីជម្រៅ៕

ពិព័រណ៍ទេសចរណ៍ និងជួញដូរអន្តរជាតិចិនឆ្នាំ ២០២២ — ដោយ ៖ កាសែតយូណានដេលី

## ពិព័រណ៍ទេសចរណ៍ និងជួញដូរអន្តរជាតិចិនឆ្នាំ២០២២ បានជំរុញការស្តារទីផ្សារវិស័យទេសចរណ៍




ពិព័រណ៍ទេសចរណ៍ និងជួញដូរអន្តរជាតិចិនឆ្នាំ២០២២ ដែលបានប្រារព្ធឡើងចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី ២៤ ខែកក្កដា ដែលបានរៀបចំពន្លាចំនួន ៧ ស្តង់ពិព័រណ៍ប្រមាណ ៤.២០០ ស្តង់ ដោយមានប្រទេសនិងតំបន់ចំនួន ៧១ ចូលរួម។ ពិព័រណ៍នេះបានបង្កើតជាវេទិកាចែករំលែក និងបង្កើតអនាគតរួមគ្នាមួយ សម្រាប់ជំរុញការស្តារវិស័យទេសចរណ៍នៃប្រទេសនានា។

ពិព័រណ៍ទេសចរណ៍ និងជួញដូរអន្តរជាតិចិនត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៨ ជាពិព័រណ៍ទេសចរណ៍អន្តរជាតិពហុមុខងារ ដែលមានទ្រង់ទ្រាយធំបំផុតជះឥទ្ធិពលយ៉ាងទូលំទូលាយបំផុត និងសហការស៊ីជម្រៅបំផុតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ហើយប្រារព្ធក្នុងមួយឆ្នាំម្តង។ ពិព័រណ៍លើកនេះ ត្រូវបានប្រារព្ធឡើងនៅទីក្រុងគុនមីង ខេត្តយូណាន ប្រទេសចិន ហើយមានប្រទេស និងតំបន់សរុបចំនួន ៧១ បានចូលរួម និងពិភាក្សាតាមអ៊ីនធើណែតឬនៅនឹងកន្លែងផ្ទាល់។ ក្នុងនោះ ពន្លាខេត្តយូណានមានខ្នាតធំជាងគេនិងរៀបចំស្តង់ពិព័រណ៍ច្រើនជាងគេ។

ពិព័រណ៍លើកនេះ ប្រារព្ធឡើងក្រោមប្រធានបទ “ការច្នៃប្រឌិតប្រកបដោយភាពឆ្លាតវៃ ដើម្បីបង្កើតអនាគតរួមគ្នា—បម្រើដល់ការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់នៃវិស័យទេសចរណ៍” នៅកន្លែងប្រារព្ធពិព័រណ៍ផ្ទាល់ បានរៀបចំពិសេសនូវពន្លាទេសចរណ៍ឆ្លាតវៃ ក្រៅពីនេះ ថែមទាំងរៀបចំពន្លាខ្នាតធំចំនួន ៦ គឺពន្លាទីតាំងគោលដៅសម្រាប់ការរស់នៅប្រកបដោយផាសុខភាព ពន្លាសហគ្រាសវប្បធម៌-ទេសចរណ៍ ពន្លាផលិតផលវប្បធម៌ ពន្លាអន្តរជាតិ ពន្លាទេសចរណ៍បែបថ្មី និងពន្លាខេត្តយូណាន។

ក្នុងអំឡុងពេលពិព័រណ៍នេះ ភាគីចូលរួមពិព័រណ៍នានា បានរៀបចំសន្និសីទផ្សព្វផ្សាយប្រធានបទពិសេសស្តីពីវប្បធម៌-ទេសចរណ៍ជាបន្តបន្ទាប់ ចំណែកឯភាគីរៀបចំពិព័រណ៍នេះ ក៏បានបើកវេទិកាស្តីពីការអភិវឌ្ឍប្រកបដោយភាពច្នៃប្រឌិតនៃទេសចរណ៍ឆ្លាតវៃ វេទិកាស្តីពីផ្លូវដែកចិន-ឡាវជំរុញការកសាងសហគមន៍វាសនារួមនៃទ្វីបអាស៊ី និងវេទិកាស្តីពីការផ្លាស់ប្តូរ និងសហប្រតិបត្តិការអភិវឌ្ឍន៍នៃទេសចរណ៍អន្តរជាតិនៅក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់(RCEP)។ លើសពីនេះ ពិព័រណ៍នេះក៏បានបន្ថែមថ្មីនូវពន្លា “ទីក្រុងវប្បធម៌អាស៊ីបូពា” និងពន្លា“សម្ព័ន្ធកិច្ចសហប្រតិបត្តិការទីក្រុងទេសចរណ៍ឡានឆាង-មេគង្គ” ដើម្បីបង្ហាញអំពីវប្បធម៌អាស៊ីបូពា និងសមិទ្ធផលនៃការអភិវឌ្ឍវប្បធម៌ និងទេសចរណ៍ក្នុងតំបន់ឡានឆាង-មេគង្គ។

ភ្ញៀវកិត្តិយសបរទេសដែលមានវត្តមាននៅក្នុងពិព័រណ៍នេះ មានសុទិដ្ឋិនិយមចំពោះកាលានុវត្តនភាពដ៏ល្អប្រសើរនៃការចូលរួមអភិវឌ្ឍន៍ទីផ្សារទេសចរណ៍ថ្មីជាមួយប្រទេសចិន ជាពិសេសខេត្តយូណាន។ លោកDaophet Chanthanasinh អគ្គកុងស៊ុលរងនៃស្ថានអគ្គកុងស៊ុលប្រទេសឡាវប្រចាំទីក្រុងគុនមីងបានបញ្ជាក់ថា “ការប្រារព្ធពិព័រណ៍លើកនេះ ជាឱកាសល្អមួយ យើងអាចផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក និងពិភាក្សាអំពីរបៀបអភិវឌ្ឍន៍វិស័យទេសចរណ៍ក្រោមស្ថានការណ៍ថ្មី ដើម្បីសម្រេចបាននូវការផ្តល់ផលប្រយោជន៍ទៅវិញទៅមក”។

នៅពេលនិយាយអំពីប្រធានបទ “RCEP+ផ្លូវដែកចិន-ឡាវ” លោកស្រី Rungtip Bookkhuntod នាយកទីស្នាក់ការប្រចាំនៅក្រុងគុនមីងនៃនាយកដ្ឋានទេសចរណ៍ជាតិប្រទេសថៃ បាននិយាយថា ប្រទេសថៃនឹងអនុវត្តការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធជាមួយប្រទេសជិតខាង។ លោកអគ្គកុងស៊ុលរងនៃអគ្គកុងស៊ុលប្រទេសជប៉ុនប្រចាំទីក្រុងឆុងឈីងសង្ឃឹមថា ឆ្លៀតឱកាសនៃពិព័រណ៍លើកនេះ ប្រទេសជប៉ុននឹងអនុវត្តការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការទេសចរណ៍កាន់តែជិតស្និទ្ធរវាងខេត្តយូណាន និងគ្រប់ទីកន្លែងទូទាំងប្រទេសចិន ដើម្បីចែករំលែកនូវកាលានុវត្តនភាពថ្មីៗ ដែលបានមកពី RCEP”ចំពោះវិស័យទេសចរណ៍ក្នុងតំបន់៕

យល់ដឹងពីបក្សកុម្មុយនិស្តចិន — ដោយ ៖ កាសែតប្រជាជនដេលី

## “គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ពិភពលោកមានសារៈសំខាន់ជាក់ស្តែងដ៏ខ្លាំងក្លា”

ឯកឧត្តម Aly Houssam El-Din Mahmoud El-Hefny អនុប្រធានសមាគមមិត្តភាពអេហ្ស៊ីប-ចិន និងជាអតីតអនុរដ្ឋមន្ត្រីការបរទេសអេហ្ស៊ីប បានទទួលកិច្ចសម្ភាសន៍ និងបានថ្លែងថា “ក្នុងស្ថានភាពជំងឺកូវីដ ១៩ បានផ្ទុះឡើងនៅលើពិភពលោក និងការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកដ៏យឺតនោះ គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ពិភពលោកដែលស្នើឡើងដោយថ្នាក់ដឹកនាំចិនមានសារៈសំខាន់ជាក់ស្តែងដ៏ខ្លាំងក្លា និងចង្អុលបង្ហាញទិសដៅសម្រាប់ប្រទេសនានាក្នុងការរួបរួម និងអភិវឌ្ឍន៍ជាមួយគ្នា”។

ឯកឧត្តមបានបន្ថែមថា “គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ពិភពលោកគឺជាផលិតផលសាធារណៈលក្ខណៈអន្តរជាតិដ៏សំខាន់មួយទៀត ដែលប្រទេសចិនផ្តល់ដល់ពិភពលោក។ វាមានគោលបំណងកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ។ វានឹងជួយពង្រឹងកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍អន្តរជាតិ ហើយពន្លឿនការអនុវត្ត «របៀបវារៈការអភិវឌ្ឍនិរន្តរភាពឆ្នាំ២០៣០នៃអង្គការសហប្រជាជាតិ»។ គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ពិភពលោកនេះ ផ្តោតលើការកសាងមតិនយោបាយដែលមនុស្សគ្រប់គ្នាឱ្យតម្លៃលើការអភិវឌ្ឍ ហើយប្រទេសទាំងអស់រួមស្វែងរកកិច្ចសហប្រតិបត្តិការជាមួយគ្នា។ ខ្ញុំយល់ស្របទាំងស្រុងជាមួយនឹងទស្សនវិស័យនេះ”។

គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ពិភពលោក ឆ្លើយតបទៅនឹងបញ្ហាជាក់ស្តែងដែលមាននៅក្នុងបុព្វហេតុនៃការអភិវឌ្ឍពិភពលោក ហើយស្វែងរកដំណោះស្រាយចំពោះបញ្ហានានា។ ឯកឧត្តមបន្តទៀតថា “នៅក្នុងវិស័យអភិវឌ្ឍន៍ ប្រទេសចិនបានយកការអភិវឌ្ឍរបស់ខ្លួនធ្វើជាគំរូ។ ប្រទេសចិនតែងតែប្រកាន់ខ្ជាប់នូវគំនិតអភិវឌ្ឍន៍ដែលចាត់ទុកប្រជាជនជាចំណុចស្នូល ទទួលបានជ័យជម្នះក្នុងយុទ្ធនាការនៃការកាត់បន្ថយភាពក្រីក្រ និងសម្រេចបាននូវគោលដៅការកាត់បន្ថយភាពក្រីក្រនៃ«របៀបវារៈការអភិវឌ្ឍនិរន្តរភាពឆ្នាំ ២០៣០ នៃអង្គការសហប្រជាជាតិ» ១០ ឆ្នាំមុនកាលកំណត់។” ឯកឧត្តមបាននិយាយបន្ថែមទៀតថា នាពេលបច្ចុប្បន្នមានប្រទេសចំនួនជាង ១០០ បានគាំទ្រគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ពិភពលោកនេះ ហើយប្រទេសចំនួន ៦០ បានចូលរួមក្នុង “ក្រុមមិត្តនៃគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ពិភពលោក” ដែលបង្កើតឡើងដោយប្រទេសចិននៅអង្គការសហប្រជាជាតិ។ នេះបង្ហាញពីការអំពាវនាវដ៏ខ្លាំងក្លានៃគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ពិភពលោក និងឆ្លុះបញ្ចាំងអំពីកង្វល់ទូទៅ និងការរំពឹងទុកនៃប្រទេសកំពុងអភិវឌ្ឍន៍។ ឯកឧត្តមបានបញ្ជាក់ថា “ខ្ញុំជឿជាក់ថា ក្រោមការខិតខំប្រឹងប្រែងរួមគ្នារបស់សហគមន៍អន្តរជាតិ គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ពិភពលោកនឹងផ្តល់ផលវិជ្ជមានកាន់តែច្រើនឡើងៗ។ ប្រាជ្ញា និងគម្រោងរបស់ប្រទេសចិនមុខជានឹងចាក់បញ្ចូលនូវទំនុកចិត្ត និងកម្លាំងចូលទៅក្នុងការស្តារឡើងវិញនូវបុព្វហេតុនៃការអភិវឌ្ឍពិភពលោកទាំងមូល”៕

ខ្សែក្រវាត់ និងផ្លូវ — ដោយ ៖ កាសែតប្រជាជនដេលី

## “ក្រោយពីស្ថានីយ៍វារីអគ្គិសនីកំចាយបានបង្កើតឡើង គ្រោះទឹកជំនន់ធំមិនដែលកើតឡើងនោះទេ”

គ្រួសាររបស់ អែ រស់នៅភូមិស្វាយធំ ក្រុងកំពត ខេត្តកំពត ប្រទេសកម្ពុជា។ លោកបានបង្កើតតូបលក់បាយក្នុងតំបន់ទេសចរណ៍ទឹកឈូខេត្តកំពត ហើយអាជីវកម្មរបស់លោកដំណើរការយ៉ាងល្អ។

ប៉ុន្តែ នៅពេលលើកឡើងពីគ្រោះទឹកជំនន់ដែលកើតឡើងកាលពីជាង ១០ ឆ្នាំមុន លោក អែ នៅតែមានអារម្មណ៍ភ័យខ្លាចជាប់ក្នុងចិត្ត។ លោកបានប្រាប់អ្នកកាសែតថា “នៅពេលនោះ រាល់រដូវវស្សាតែភ្លៀងខ្លាំងបន្តិច ទឹកទន្លេកំចាយក៏ឡើងខ្លាំង ហើយកើតគ្រោះទឹកជំនន់ ក្រុងកំពតដែលស្ថិតនៅខាងក្រោមទន្លេកំចាយ តែងតែត្រូវបានលិច។ ប៉ុន្តែ ក្រោយពីស្ថានីយ៍វារីអគ្គិសនីកំចាយបានបង្កើតឡើងមក គ្រោះទឹកជំនន់ធំៗមិនដែលកើតឡើងម្តងទៀតនោះទេ”។

ស្ថានីយ៍វារីអគ្គិសនីកំចាយស្ថិតនៅទន្លេកំចាយខាងលើ វិនិយោគ និងកសាងដោយក្រុមហ៊ុន Power Construction Corporation of China, Ltd បានដាក់ឱ្យដំណើរការជាផ្លូវការនៅខែសីហា ឆ្នាំ ២០១២។ ស្ថានីយ៍វារីអគ្គិសនីនេះមានកម្លាំងផលិតអគ្គិសនីសរុប ១៩៤,១ មេហ្គាវ៉ាត់ និងផលិតថាមពលអគ្គិសនីជាមធ្យមប្រចាំឆ្នាំដល់ ៤៩៨ លានគីឡូវ៉ាត់មួយម៉ោង(kW·h)។ ក្នុងរដូវវស្សា ទំនប់វារីអគ្គិសនីកំចាយដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាទឹក ដែលអាចកាត់បន្ថយការជន់លិច ហើយក្នុងរដូវប្រាំង ទំនប់នេះក៏អាចដើរតួនាទីគ្រប់គ្រងដើម្បីធានាលំហូរទឹកនៃទន្លេ។ លោកបន្ថែមទៀតថា “ស្ថានីយ៍វារីអគ្គិសនីកំចាយមិនត្រឹមតែមានមុខងារគ្រប់គ្រងទឹកជំនន់ប៉ុណ្ណោះទេ ថែមទាំងអាចជួយយើងដោះស្រាយបញ្ហាទឹកស្អាតសម្រាប់បរិភោគផងដែរ”។

គិតដល់បច្ចុប្បន្ននេះ ស្ថានីយ៍វារីអគ្គិសនីកំចាយបានដំណើរការផលិតដោយសុវត្ថិភាពជាង ៣.៨០០ថ្ងៃ ហើយវាបានក្លាយទៅជាផ្នែកសំខាន់តាមបណ្តាញអគ្គិសនីកម្ពុជាសម្រាប់ផ្គត់ផ្គង់ថាមពលកំពូល និងទទួលបានពិន្ទុពេញលេញក្នុងការស្ទង់មតិអតិថិជនរបស់បណ្តាញជាតិកម្ពុជារយៈពេល ៤ ឆ្នាំជាប់គ្នា។ លោក វ៉ិត វឌ្ឍនា ជាអភិបាលរងខេត្តកំពត បានវាយតម្លៃថា“ស្ថានីយ៍-វារីអគ្គិសនីកំចាយ មិនត្រឹមតែអាចផ្តល់ថាមពលនិងបំភ្លឺទីនេះនៅពេលរាត្រីប៉ុណ្ណោះទេ ថែមទាំងអាចកាត់បន្ថយគ្រោះមហន្តរាយទឹកជំនន់ និងជំរុញការលើកកម្ពស់សមត្ថភាពគ្រប់គ្រងទឹកជំនន់ក្នុងតំបន់ ក៏ដូចជាឆ្លើយតបគ្រោះអាសន្នផងដែរ”៕

អ្នកនិពន្ធភាសាចិន៖ HE RONG អ្នកនិពន្ធភាសាខ្មែរ៖ SHEN YAN LI ZHA រចនារូបភាព៖ SUN YONGGANG